# អាយុបាន ៤ ឆ្នាំ

**កូនខ្ញុំ...**

- [ ] ចេះផ្គូរផ្គងវត្ថុ ឬពណ៌ផ្សេងៗគ្នា ចេះរាប់លេខ ១ ដល់ ១០ (អាចប្រើដុំឈើ ឬស្លាបព្រាក្នុងការរាប់) ហើយអាចចង្អុលទៅចំនួនលេខបាន
- [ ] ចេះប្រើពាក្យពីអតីតកាលដូចជា (បានមួរឡើង ឬបានកាន់យក) អាចនិយាយច្បាស់ (ដែលអ្នកដទៃងាយយល់) ចេះដឹងពី ៤-៨ ឥរិយាបថ
- [ ] ចេះញញឹម សើច ចំពោះរូបភាពកំប្លែង អាចលេងចុះសម្រុងជាមួយក្មេងដទៃទៀត យល់ដឹងនៅពេលមនុស្សម្នាក់ឈឺចាប់ ឬត្រូវការជំនួយ
- [ ] ចេះចងខ្សែស្បែកជើង ពាក់ខ្សែក្រវាត់ ចេះប្រើសម (អាចកាន់ដោយប្រើនឹងម្រាមដៃ)
- [ ] ចេះរត់ ចេះឈរហ្អឹងជើងមួយ រត់កាត់ជួរ ឬរត់កាត់ផ្លូវ ។

# អាយុបាន ៤ ឆ្នាំកន្លះ

**កូនខ្ញុំ...**

- [ ] អាចទន្ទេញលេខបានចំនួន ៤ ហើយអាចផ្គុំវត្ថុដែលត្រូវផ្គុំចូលគ្នាបាន អាចជ្រើសរើសក្រុមណាមួយដែលមាន "បាល់ច្រើនជាង ពែងច្រើនជាង"
- [ ] អាចប្រាប់អ្នកពីមូលហេតុ ឬអាចនិយាយប្រាប់លោកអ្នកនូវអ្វីមួយដែលកើតឡើងដោយសារអ្វី ដោយប្រើប្រយោគមាន ៥-៦ ពាក្យ អាចដឹងពណ៌បាន ៤ ពណ៌
- [ ] ចេះចែករំលែក ទទួលវេនបន្ត បញ្ចេញប្រាប់អោយគេដឹងថាខ្លួនវាអាចធ្វើអ្វីមួយបាន
- [ ] ចេះជួយខ្លួនឯង ចេះជូត និងរើសអ្វីៗដែលខ្លួនធ្វើកំពប់ និងចេះស្លៀកពាក់ដោយខ្លួនឯង
- [ ] ចេះជិះទោងយោលលេង ចេះលោតជើងមួយដោយស្ទាត់ជំនាញ អាចទាត់បាល់ធំៗបាន ហើយអាចភ្ជាប់ ឬគូរពីចំណុចមួយទៅចំណុចមួយបានដែលមាននៅលើក្រដាស

# អាយុបាន ៥ ឆ្នាំ

**កូនខ្ញុំ...**

- [ ] ដឹងពីតម្លៃប្រាក់កាក់ ៣ ហើយអាចពន្យល់ប្រាប់ពីន័យរបស់ពាក្យចំនួន ៥ បាន ចេះរាប់ចំនួនពី ៤ ឡើងទៅ ហើយអាចឆ្លើយនឹងសំណួរថា "ចំនួនប៉ុន្មាន?"
- [ ] អាចទាក់ទងជាមួយអ្នកដទៃ ចេះប្តូរពាក្យដែលនិយាយទៅនឹងរូបភាព ហើយអាចប្រាប់អ្នកនូវអ្វីដែលមានភាពដូចគ្នា ឬខុសពីគ្នា (រវាងទម្រង់ប្រដាប់លេង រូបភាពលើបៀ)
- [ ] អាចប្រាប់ពីថ្ងៃកំណើតរបស់ខ្លួនឯងបាន អាចប្រាប់អំពីទឹកចិត្ត ២ យ៉ាង (សប្បាយ ឬអន់ចិត្ត) អាចប្រាប់លោកអ្នកពីភាពខុសគ្នារវាងបានថាអ្វីជាការពិត និងអ្វីជាការមិនពិត
- [ ] អាចពាក់អាវដោយខ្លួនឯង ហើយដឹងថាខាងណាមុខខាងណាក្រោយ ចេះដុសធ្មេញដោយខ្លួនឯង
- [ ] អាចចាប់ ឬបោះបាល់ លោតរំលង ចេះគោះទៅតាមចង្វាក់ភ្លេង ចេះគូសតាមសញ្ញាជើងក្អែក (+) ចេះគូសរូបរាងមនុស្ស (ជាដងខ្លួន ដៃជើង ម្រាមជារាងគំនូសត្រង់ៗ និងមូលៗសម្រាប់ដៃ ជើង ក្បាល ម្រាមដៃ)

បើសិនជាលោកអ្នកមិនមានសញ្ញា ✔ នៅដើមឃ្លានិមួយៗសម្រាប់អាយុកូនរបស់លោកអ្នក... ឬ លោកអ្នកមានកង្វល់ណាមួយ...សូមទូរស័ព្ទទៅកម្មវិធី **EI** ឬ **CONNECT** ប្រចាំតំបន់លោកអ្នក តាមលេខ **1-800-692-7288** ដើម្បីនិយាយជាមួយ មួយក្នុងបណ្តាអ្នកឯកទេសអំពីកុមាររបស់យើងខ្ញុំ ។





# ចំណុចសំខាន់ៗដប់យ៉ាង

## សម្រាប់ការចិញ្ចឹមកូនឱ្យកាន់តែរីករាយ កាន់តែមានសុខភាពល្អ

**ផ្តល់ភាពកក់ក្តៅ ស្រឡាញ់ និងយកចិត្តទុកដាក់**

កាលណាក្មេងទទួលបានភាពកក់ក្តៅ ការថៃទាំស្រឡាញ់ វានឹងមានសេចក្តីសុខស្រួល និងទុកចិត្តចំពោះលោកអ្នកដែលអ្នកថែរក្សាវា ។

**ឆ្លើយតបចំពោះអក្សរ និងសញ្ញារបស់កូន**

ទទួលស្គាល់ និងឆ្លើយតបចំពោះសម្លេង ចលនា និងទឹកមុខដែលកូនរបស់អ្នកធ្វើ ។ នេះនឹងជួយអោយវាមានការជឿទុកចិត្ត និងមានភាពស្និទ្ធិស្នាលជាមួយលោកអ្នក ។

**និយាយ ច្រៀង និងអានអោយកូនស្តាប់**

កិច្ចការទាំងនេះជួយដល់ស្មារតីកូនលោកអ្នកឱ្យធ្វើការទំនាក់ទំនង តាមដែលវាត្រូវការ សម្រាប់ការរីកលូតលាស់ និងការសិក្សានាពេលបច្ចុប្បន្ន និងទៅអនាគត ។

**ទម្លាប់អោយកូនមានរបៀបជាប្រចាំ**

បង្រៀនកូនលោកអ្នកពីម៉ោងពេលចូលគេង និងទម្លាប់វាអោយបានទៀងទាត់ ប្រៀបដូចជាច្រៀងបទចម្រៀង និងបិទភ្លឺងននពេលចូលគេង ។ ទម្លាប់បែបនេះរាល់ថ្ងៃ គឺអាចធ្វើអោយក្មេងមានការកក់ក្តៅ និងសប្បាយរីករាយ ។

**ជំរុញអោយកូនលេងដោយមានការប្រុងប្រយ័ត្ន**

ពេលណាកូនលោកអ្នកធំលូតលាស់ គេនឹងធ្វើការស្វែងរកនូវពិភពមួយដែលអ្នកថែរក្សា គេមិនបាននឹកដល់ ។ សុំលោកអ្នកជួយជំរុញការរុករកនេះផង។ យើងប្រហែលជាគិតថា ការសិក្សាគឺត្រូវមានភាពច្បាស់លាស់មួយ ប៉ុន្តែក្មេងរៀនសូត្រតាមរយៈការលេងនេះឯង ។

**ជ្រើសរើសកម្មវិធីទូរទស្សន៍ល្អៗអោយកូនមើល**

មើលទូរទស្សន៍ជាមួយកូន និងពន្យល់ប្រាប់កូនពីអ្វីដែលអ្នកកំពុងមើល ។ កុំយកទូរទស្សន៍ជាអ្នកមើលថែរក្សាក្មេងអោយសោះ ។

**ប្រើវិន័យជាមធ្យោបាយសំរាប់អប់រំកូន**

បន្ថែមទៅលើការស្រឡាញ់ សូមលោកអ្នកបង្រៀនកូនអោយស្គាល់នូវកម្រិតព្រំដែននៃការស្រឡាញ់នេះផង ។ ប៉ុន្តែមិនត្រូវវាយ ឬចាប់កន្ត្រាក់ទាញកូនឡើយ ។

**ទទួលស្គាល់ថាក្មេងម្នាក់ៗមានចរិតខុសៗគ្នា**

ក្មេងៗលូតលាស់ដោយល្បឿនខុសៗគ្នា ។ គំនិត និងអាកប្បកិរិយាក្មេងគឺអាចបង្ហាញអោយឃើញអំពីអាកប្បកិរិយារបស់ឪពុកម្តាយ និងអ្នកថែរក្សាចំពោះរូបគេ ។

**ជ្រើសរើសការថែទាំមានគុណភាព និងចូលរួម**

សូមលោកអ្នកឧស្សាហ៍ទៅលេងនឹងអ្នកមើលថែរក្សាកូនអ្នកអោយបានញឹកញាប់ផង និងរកនរណាម្នាក់ដែលឆ្លើយតបយ៉ាងកក់ក្តៅ និងយល់ពីសេចក្តីត្រូវការរបស់កូនលោកអ្នក ។

**ត្រូវចេះថែរក្សាខ្លួនលោកអ្នកផ្ទាល់**

ឪពុកម្តាយក៏ត្រូវការថែរក្សាសុខភាពរបស់ខ្លួនដែរ ។ បើកាលណាលោកអ្នកហត់នឿយ ឬមួរម៉ៅធុញថប់ខ្លាំងពេក គឺលោកអ្នកនឹងមានការលំបាកចំពោះសេចក្តីត្រូវការរបស់កូនអ្នក ។

"ចំណុចសំខាន់ៗទាំងដប់" នេះត្រូវបានរៀបចំឡើងដោយយុទ្ធនាការ I Am Your Child ថ្នាក់ជាតិ។ គោលបំណងរបស់ពួកគេ គឺជំរុញការលូតលាស់របស់កុមារជាអាទិភាពខ្ពស់សម្រាប់ជាតិទាំងមូល ។

សម្រាប់ព័ត៌មានបន្ថែមពីអ្វីដែលឪពុកម្តាយ និងអ្នកថែរក្សាអាចធ្វើដើម្បីជម្រុញការអភិវឌ្ឍន៍សុខភាពកូនក្មេង សូមពិនិត្យមើលតាមគេហទំព័រ I Am Your Child (www.iamyourchild.org) ឬសរសេរទៅកាន់ : I Am Your Child, P.O. 15605, Beverly Hills, CA 90209

កូនសៀវភៅ "Watch Me Grow" នេះ ត្រូវបានបង្កើតឡើងនៅក្នុងរដ្ឋ Philadelphia ក្រោមកិច្ចសហការពី: សាជីវកម្មគ្រប់គ្រងសុខភាពសាធារណៈ/ChildLink (PHMC) សេវាកម្មផ្នែកវិកលចរិកនៃរដ្ឋ Philadelphia (MRS) ក្រសួងសុខភាពសាធារណៈនៃរដ្ឋ Philadelphia (PDPH) និងក្រុមប្រឹក្សាសំរបសំរួលអន្តរទីភ្នាក់ងារនៃរដ្ឋ Philadelphia (PICC). តំលាតសំរាប់កំណើត ៥ ឆ្នាំ ត្រូវបានគេទាញចេញពីលេខមួយនៃការធ្វើតេស្តមើលការវិវឌ្ឍន៍ តាមបទដ្ឋានសំរាប់ទារក ក្មេងៗ និងកុមារតូចៗ មួយចំនួន។ រៀបចំក្រាហ្វិកដោយ Trinh Loi ។

# សូមមើលទំព័រខាងក្នុងនូវអ្វី ដែលកូនលោកអ្នកអាចធ្វើបាន




ការរីកលូតលាស់របស់កូនក្មេងក្នុងដំណាក់កាលដំបូងគឺចូលចិត្តរៀននូវអ្វីដែលប្លែកថ្មីៗ ។ ការរីកលូតលាស់នោះ គឺមានលក្ខណៈខុសៗគ្នាក្នុងកំឡុងពេល ៦ ខែ ។ ប្រសិនបើលោកអ្នកមានការព្រួយបារម្ភអំពីការលូតលាស់របស់កូនលោកអ្នក សូមទូរស័ព្ទមកកម្មវិធីអន្តរាគមន៍វ័យកុមារភាព (EI) ។

**pennsylvania**
EARLY INTERVENTION

*Serving Children with Developmental Delays*

**...ជំនួយគ្រួសារអភិវឌ្ឍសក្តានុពលកូនរបស់ពួកគេ**

មូលនិធិសម្រាប់កម្មវិធីអន្តរាគមន៍កុមារភាព ត្រូវបានផ្តល់ជូនតាមរយៈ: Pennsylvania OCDEL (ការិយាល័យអភិវឌ្ឍន៍កុមារ និងការរៀនសូត្រនៅបឋមវ័យ) ការិយាល័យ OMR ប្រចាំតំបន់សំរាប់សេវាកម្មអភិវឌ្ឍន៍ Intermediate Unites និងបណ្តាទីភ្នាក់ងារ EI ដែលមានកិច្ចសន្យាជាមួយរដ្ឋ/តំបន់។

**ខ្សែទូរស័ព្ទរបស់ CONNECT ទូទាំងរដ្ឋ: 1-800-692-7288**

មានជាភាសាផ្សេងៗទៀត – អារ៉ាប់ បារាំង ព័រទុយហ្គាល់ អេស្ប៉ាញ ចិន កូរ៉េ វៀតណាម ខ្មែរ រុស្ស៊ី និងគ្រីអូលហៃទី ។



១. សូមសង្កេតមើលកូនទៅតាមអាយុរបស់វា ។
២. ប្រសិនបើកូនលោកអ្នកអាចធ្វើអ្វីបានចាប់ពីពីរឡើងទៅ សូមគូសសញ្ញា ☑ ។
៣. គំនូស ☑ នៅក្នុងប្រអប់នីមួយៗ មានន័យថាកូនលោកអ្នកអាចធ្វើបានអ្វីមួយទៅតាមអាយុរបស់វា ។ ឥតគិតថ្លៃ ។
៤. បើសិនជាលោកអ្នក មានប្រអប់ដែលមិនមាន ☑ សូមទូរស័ព្ទទៅ **CONNECT** ឬកម្មវិធី **EI** ប្រចាំតំបន់លោកអ្នក ។

## ចាប់ពីកើតរហូតដល់ ៣ ខែ

**កូនខ្ញុំ...**

☐ អាចចំណាំខ្ញុំបាន អាចងាកក្បាលមើលតុក្កតាកម្រើក អាចញញឹមបាន

☐ អាចបញ្ចេញសម្លេងខ្លះៗដូចជា អ្ហូ..អា..រ ហើយអាចងាករកមើលសម្លេងដែលខ្ញុំនិយាយ អាចសើចក្អឹកៗបាន

☐ អាចសម្លឹងទៅរកមនុស្សដែលនិយាយជាមួយវា អាចវេភ្នែកមើលមកខ្ញុំ ចេះបង្ហាញការរីករាយ ឬការមិនពេញចិត្តរបស់វាផងដែរ

☐ អាចបៀមម្រាមដៃ អាចក្តាប់ដៃម្តាយជាប់ ឬអាចទ្រដបបាននៅពេលវាបៅទឹកដោះគោ

☐ អាចចេះងើយក្បាល ក្រឡាប់ខ្លួន ឬអាចចេះកាន់ប្រដាប់ក្រឡុកលេងខ្លះៗ

## អាយុចាប់ពី ៣-៦ ខែ

**កូនខ្ញុំ...**

☐ អាចសម្លឹងមើលដៃរបស់វា និងវត្ថុដែលនៅជុំវិញខ្លួនវា អាចចំណាំសម្លេងដែលខ្លួនធ្លាប់ឮ ហើយអាចឈោងចាប់យក ឬកាន់រលាក់របស់លេងផ្សេងៗ

☐ អាចចេះនិយាយប៉ប៉ិចប៉ប៉ុចដូចជា បា....ដា....មា....អាចសើច ឬងាកទៅរកសម្លេងបាន

☐ អាចញញឹមប្រសិនបើលោកអ្នកញញឹមដាក់វា និងចេះបង្ហាញអ្វីដែលវាមិនពេញចិត្តដូចជាបាត់ប្រដាប់លេង ហើយចេះឆ្លើយឆ្លងជាមួយខ្ញុំជាងអ្នកផ្សេងៗ

☐ បង្ហាញចំណូលចិត្តចំពោះម្ហូបអាហារជាងទឹកដោះគោ រំភើបនៅពេលណាមានបញ្ចុកចំណី ចេះជញ្ជក់ និង លិតអាហារញុាំពីស្លាបព្រាបាន

☐ អាចផ្តុំដៃទាំងពីរនៅចំកណ្តាល អាចចេះលេងជាមួយម្រាមជើងខ្លួនឯង ចេះទ្រក្បាលឡើង អាចក្រឡាប់ (ពីខ្នងមកពោះវិញ)

## អាយុចាប់ពី ៦-៩ ខែ

**កូនខ្ញុំ...**

☐ អាចចេះបោះបាល់ ចេះទំលាក់ ឬរកប្រដាប់លេង ធ្វើចលនាត្រាប់តាមសម្លេង

☐ អាចឈប់ភ្លាមប្រសិនបើនិយាយថា "ទេ" ចេះត្រាប់តាមសម្លេង ប្រសិនបើអ្នកហៅ គឺអាចងាកក្បាលមករក ឬញញឹម

☐ អាចចេះលេងតុក្កតាដោយខ្លួនឯង អាចធ្វើតម្រាប់តាមលោកអ្នក (អាចធ្វើសញ្ញាថា លាហើយ លេង "ធំណាស់") ចង់នៅជិតម្តាយ ហើយបោះដៃចេញពីអ្នកដែលវាមិនស្គាល់

☐ អាចកាន់កែវបានបើមានអ្នកជួយ ចេះផ្ទេររបស់ពីដៃម្ខាងទៅម្ខាងទៀត ចេះញុាំខ្លួនឯង (ប្រើម្រាម)

☐ អាចចេះអង្គុយ ចេះលូនលើពោះ ហក់លោតដោយប្រើជើង (ជើងមិនរឹងខ្លាំង) វារអាចតោងឈរបាន

## អាយុចាប់ពី ៩-១២ ខែ

**កូនខ្ញុំ...**

☐ អាចចេះចង្អុល ចេះគោះប្រដាប់តុក្កតាលេង ឬតុ ចូលចិត្តមើលសៀវភៅរូបភាព

☐ យល់ពាក្យខ្លះៗក្រៅពីពាក្យ ម៉ា...ដាៗ...ចេះហុចរបស់អោយបើលោកអ្នកសុំ ចេះធ្វើត្រាប់តាមសម្លេងដូចជាក្តក់ ឬក្អក

☐ ចេះធ្វើចលនាដើម្បីអោយបានសើច ចេះស្រវាអោបលេងជាមួយក្មេងដទៃទៀត ចូលចិត្តលេងបិទពួន

☐ អាចចេះញិញអញ្ចាញធ្មេញខ្លួនឯងលេង ចេះប្រាន រុញ ទាញរបស់ផ្សេងៗ ហៀរទឹកមាត់តិច (លើកលែងតែនៅពេលញិញធ្មេញ)

☐ អាចចេះក្រោកឈរដោយខ្លួនឯងបាន វារបានរហ័ស តោងជណ្តើរពីរ ឬបីកាំ ចេះបោះបាល់ ឬទះស្បោងលេង

## អាយុចាប់ពី ១២-១៥ ខែ

**កូនខ្ញុំ...**

☐ ចេះរៀបបន្តុបដុំឈើ ចេះប្រើដៃធ្វើចលនាពេលដែលវាចង់ធ្វើ ចេះចង្អុលរូបនៅក្នុងសៀវភៅរូបភាព

☐ ចេះនិយាយ ២ ទៅ ៣ ពាក្យ ឬបញ្ចេញសម្លេងនៅពេលនិយាយ ចេះងាករករបស់ប្រសិនបើត្រូវបានសួរ "នៅឯណា... ?"

☐ ចេះបោះបាល់ត្រឡប់មកលោកអ្នកវិញ ចេះធ្វើត្រាប់តាមអ្វីដែលលោកអ្នកធ្វើ ចេះជ្រើសរើសតុក្កតាលេង

☐ អាចចេះបើកទំព័រសៀវភៅ ចេះជួយនៅពេលលោកអ្នកស្លៀកពាក់អោយវា ចេះកាន់ស្លាបព្រាបាន (ប៉ុន្តែនៅកំពប់)

☐ អាចចេះដើរ ចេះវារឡើងជណ្តើរ (ដោយដៃ និងជង្គង់) ចេះរើសគ្រាប់តូចៗដូចជា ឈេរៀស (ដោយប្រើមេដៃ និងម្រាមដៃ)

## អាយុចាប់ពី ១៥-១៨ ខែ

**កូនខ្ញុំ...**

☐ ចេះហៅឈ្មោះរបស់អ្វីមួយ ចេះរកមើលប្រដាប់លេងដែលនៅក្រោមតុ ឬក្រោមទូ ហើយចេះបើកទូរកមើលរបស់ទៀតផង

☐ ចេះនិយាយពី ៥ ទៅ ៦ ពាក្យ ហើយចេះចង្អុលទៅរូបភាពក្នុងសៀវភៅប្រាប់អំពីឈ្មោះរូបនោះ

☐ ចេះស្តាប់តាមបញ្ជាធម្មតា (ទៅយកបាល់ ឬរបស់អ្វីមួយប្រសិនបើលោកអ្នកចង្អុលទៅរបស់នោះ)

☐ ចូលចិត្តកាន់ ឬអោបកូនតុក្កតា ចេះហៅអោយជួយ (បើកប្រអប់ ឬមួលប្រដាប់លេង) រំភើបចំពោះអ្វីៗដែលខ្លួនវាអាចធ្វើកើត

☐ ចេះដោះស្រោមជើងខ្លួនឯង ចេះរើសប្រដាប់លេងដាក់ក្នុងកន្ត្រក ឬចាក់ពីកន្ត្រកវិញ ចេះរត់ (តេះតះ ជើងរឹង) ចេះវារឡើងជណ្តើរបើមានលោកអ្នកជួយ និងចេះបោះគ្រវែងលេងរបស់អ្វីមួយ

## អាយុចាប់ពី ១៨-២១ ខែ

**កូនខ្ញុំ...**

☐ អាចចេះតម្រៀបដុំឈើ ៤-៦ ដុំ ចង្អុលទៅវត្ថុនោះប្រសិនបើត្រូវបានសួរ ("ច្រមុះ ភ្នែករបស់វានៅឯណា?") ហើយចេះហៅឈ្មោះខ្លួនវាទៀតផង

☐ ចេះនិយាយពាក្យពី ៦-១០ ពាក្យ ចេះប្រើពាក្យ "ខ្ញុំ ម៉ាក់" ចេះប្រើពាក្យហៅអ្វីៗ ដែលខ្លួនវាស្គាល់

☐ ចេះបង្ហាញនូវអារម្មណ៍របស់វា ចាប់ផ្តើមចេះមានកម្មសិទ្ធិ ("របស់ខ្ញុំ") ហើយចេះធ្វើតម្រាប់តាមមនុស្សដទៃទៀតដែលធ្វើអ្វីមួយ

☐ អាចចេះរៀបទុករបស់របរដែលគូសលេងហើយ (ដោយមានជំនួយ) ហើយចេះដោះខោអាវ និងចេះកាន់កែវបានល្អ

☐ ចេះទាត់បាល់ ឬចេះលោតចុះតាមជណ្តើរដោយតោងដៃលោកអ្នក ចេះកាន់ខ្មៅដៃផាត់ពណ៌ (ក្នុងកណ្តាប់ដៃ)

## អាយុពី ២១-២៤ ខែ

**កូនខ្ញុំ...**

☐ ចេះរៀបបន្តុបដុំកូនឈើ ឬកំប៉ុងជា ៦ ជួរ ចេះរៀបចំជួយទុកដាក់របស់របរអាចចេះត្រាប់ធ្វើជាសម្លេងសត្វផ្សេងៗ ។

☐ ចេះនិយាយពាក្យខ្លះ ហើយអាចយល់នូវពាក្យដែលគ្នាចង់និយាយ យល់ដឹងនូវពាក្យច្រើនជាង ២០ ពាក្យ ប្រើប្រាស់ ២ ពាក្យរួមគ្នា ("ទឹកផ្លែឈើទៀត")

☐ ចេះស្តាប់រឿងនិទាន (ឬលេងដោយខ្លួនឯង) ក្នុងរយៈពេលខ្លី ចេះអើពើយកចិត្តទុកដាក់បង្ហាញនូវភាពជឿទុកចិត្តខ្លួនឯង ("ខ្ញុំធ្វើវា" "ទេ")

☐ ចេះកាន់ប្រើស្លាបព្រាបានល្អ អាចចេះកាន់កែវទឹកបានល្អមិនសូវកំពប់ ហើយចេះពាក់ស្បែកជើងដោយខ្លួនឯងបាន ។

☐ ចេះលោតលេងនៅលើក្តារដោយជើងទាំងពីរ ហើយអាចកាន់កែវទឹកនៅដៃម្ខាង ចេះគូសជារូបគំនូររង្វង់អ្វីមួយ ។

## អាយុបាន ២ ឆ្នាំកន្លះ

**កូនខ្ញុំ...**

☐ ចូលចិត្តលេងត្រាប់ដូចជា (បញ្ចុកចំណីអោយតុក្កតា យកដុំឈើអ្វីមួយធ្វើជាទូរស័ព្ទ) ដឹងច្បាស់អំពីវត្ថុនីមួយៗយ៉ាងហោចណាស់បី ("តើសោឡានសម្រាប់ធ្វើអ្វី?") ឬក៏ផ្នែកបីនៃរាងកាយតាមអ្វីដែលពួកគេធ្វើ ("តើយើងមើលឃើញដោយសារអ្វី ?")

☐ អាចយកពាក្យបីមកផ្តុំជាឃ្លា (ខ្ញុំទៅផង) ចេះអាក់អន់ចិត្តបើគេមិនយល់អំពីគោលបំណងវា ចេះសួរសំណួរធម្មតាខ្លីៗ

☐ ចេះរើសទុកប្រដាប់ប្រដាលេងរបស់ខ្លួន ប៉ុន្តែនៅមានការឆ្លងមិនសូវមានការអត់ធ្មត់ឡើយ

☐ អាចចេះដុសធ្មេញ ស្លៀកពាក់ ចេះលាងដៃបានប្រសិនបើលោកអ្នកជួយ

☐ ចេះរត់ដោយងាយស្រួល ដើរចង្អៀត ចេះកាន់ខ្មៅដៃផាត់គូសវាសដោយខ្លួនឯងបាន ចេះបើកសៀវភៅមើលម្តង ១ សន្លឹក

## អាយុបាន ៣ ឆ្នាំ

**កូនខ្ញុំ...**

☐ អាចចេះត្រាប់តាមចលនា (ដូចជាញាក់ត្របកភ្នែក ធ្មេចភ្នែក ឬទះថ្ពាល់ខ្លួនឯងលេង) ចេះដោះស្រាយបញ្ហាខ្លះ (យកកៅអីឡើងឈោងចាប់យករបស់អ្វីមួយដែលយកដោយដៃមិនដល់) ដឹងច្បាស់អំពីសម្លេងនីមួយៗ (សម្លេងផ្គរលាន់ ឬកណ្តឹងរោទិ៍)

☐ អាចចេះច្រៀង និងនិយាយប៉ប៉ិចប៉ប៉ោច អាចផ្តុំពាក្យពី ៣-៤ រៀបជាឃ្លាដើម្បីពន្យល់អោយគេយល់អំពីបំណងរបស់ខ្លួន

☐ ចេះលេងសប្បាយជាមួយក្មេងដទៃទៀត ចេះមានការអៀនប្រៀនចំពោះមនុស្សដែលខ្លួនមិនស្គាល់ ចេះស្តាប់តាមវិន័យ

☐ ចេះពាក់អាវរងារ និងស្បែកជើងផ្ទាត់ដោយខ្លួនឯង និងចេះកាន់កន្ត្រៃ (ក្រោមការឃ្លាំមើលពីលោកអ្នក) ចេះប្រើសម (កាន់ក្នុងកណ្តាប់ដៃ)

☐ ចេះលោតដោយអង្គុញជើង (ជើងទាំងពីរនៅពេលតែម្តង) អាចឡើងជណ្តើរបានដោយបោះជំហានម្តងមួយៗ (ប្រើប្រាស់ជើងម្តងមួយ) ហើយអាចត្រាប់ដោយបង្វិលខ្លួនជុំវិញបាន

## អាយុបាន ៣ ឆ្នាំកន្លះ

**កូនខ្ញុំ...**

☐ យល់អំពីលេខដែលមានចំនួន ២ (ដូចជា នំ ២ ឡាន ២) អាចយល់អំពីពណ៌ ហើយអាចផ្គូរផ្គងត្រូវនឹងរាងវត្ថុផ្សេងៗ

☐ យល់ពាក្យថាធំជាង តូចបំផុត ទន់ រឹង....ងាយស្រួលក្នុងការឆ្លើយសំណួរ ចាប់ផ្តើមយល់ ឬប្រើពាក្យដូចជា "ខាងលើ ខាងក្រោម"

☐ ចេះចំណាំខ្លួនឯងក្នុងរូបថត ចេះសុំធ្វើការកំប៉ិចកំប៉ុក (ដូចជាការកាន់អំបោស ឬជូតតុ) ហើយអាចអោយយើងដឹងថាវាសប្បាយចិត្ត ខឹង ឬ ខ្លាច ។ល។

☐ ចេះទាញពាក់ស្រោមជើង ដោះខ្សែរអាវ ចេះពាក់ខ្សែក្រវ៉ាត់ អាចទៅបន្ទប់ទឹក ឬបង្គន់ដោយខ្លួនឯងបាន

☐ អាចឈរជើងមួយទ្រដងខ្លួនឯងបាន អាចគូសជារាងការ៉េបាន អាចចុះជណ្តើរឆ្លាស់ជើង

**...ជំនួយគ្រួសារអភិវឌ្ឍសក្តានុពលកូនរបស់ពួកគេ**

## តើកម្មវិធីអន្តរាគមន៍កុមារភាព (EI) គឺជាអ្វី?

កម្មវិធីអន្តរាគមន៍កុមារភាព (EI) មានសេវាកម្ម និងការគាំទ្រជាច្រើនដែលគេរៀបចំឡើងដើម្បីជួយគ្រួសារ ទាំងឡាយដែលមានកូនមានការវិវឌ្ឍន៍ឬលូតលាស់យឺតយ៉ាវ ។ ខណៈពេលដែលក្មេងទាំងអស់មានការលូតលាស់ និងផ្លាស់ប្តូរទៅតាមដំណើររបស់ពួកគេ ក្មេងខ្លះអាចជួបប្រទះនឹងការយឺតយ៉ាវក្នុងដំណើរវិវឌ្ឍន៍ របស់ខ្លួន ។ ជូនកាលបញ្ហានេះអាចក្លាយជាក្តីកង្វល់មួយ ។ កម្មវិធីអន្តរាគមន៍កុមារភាព ផ្តល់ការគាំទ្រ និងសេវាកម្មនានាដល់ក្មេងៗតូចៗ និងគ្រួសារ/អ្នកមើលថែទាំរបស់ពួកគេ ក្នុងការជួយធ្វើឱ្យក្មេងលូតលាស់ និងវិវឌ្ឍបានល្អ ។





## តើនរណាខ្លះដែលមានសិទ្ធិទទួលបាន?

ទារក ក្មេងៗ និងកុមារា កុមារីមិនទាន់ទៅរៀន ដែលមានតំរូវការពិសេស ដោយសារការយឺតយ៉ាវ ខាងការវិវឌ្ឍន៍ ឬការធ្វើរោគវិនិច្ឆ័យ មានសិទ្ធិទទួលបានសេវាកម្មពីកម្មវិធីអន្តរាគមន៍កុមារភាពនេះ ។

## តើសេវាកម្ម និង ការគាំទ្ររបស់កម្មវិធីកុមារភាព មានអ្វីខ្លះ?

សេវាកម្ម និង ការគាំទ្រនៃកម្មវិធីអន្តរាគមន៍កុមារភាព (EI) ត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃទៅដល់គ្រួសារទាំងឡាយ ។ សេវាកម្មរបស់ EI អាចរួមមាន: ព័ត៌មានអំពីរបៀបដែលក្មេងៗអភិវឌ្ឍជំនាញ និង សមត្ថភាព អប់រំនិងគាំទ្រដល់ឪពុកឬម្តាយ/អ្នកមើលថែទាំ និងការព្យាបាលជាក់លាក់ណាមួយសំរាប់ការវិវឌ្ឍន៍ ដែលគេរៀបចំឡើងសំរាប់កូនរបស់ពួកគេ ។ កម្មវិធីអន្តរាគមន៍កុមារភាព ផ្តល់ជាគំនិតនានា សំរាប់គ្រួសារមួយអាចជួយកូនរបស់ពួកគេនៅឯផ្ទះ ក៏ដូចជានៅក្នុងសហគមន៍ ហើយត្រូវបានគេតំរូវទៅតាមបុគ្គលនីមួយ ដើម្បីជំរុញទាំងការលូតលាស់ និងការរៀនសូត្ររបស់ក្មេង ។ បើសិនជាក្មេងម្នាក់កំពុងចូលក្នុងកន្លែងអប់រំ/ថែទាំកុមារ នោះគ្រូ/អ្នកព្យាបាល/អ្នកជំនាញរបស់កម្មវិធី EI អាចជួយផ្តល់យុទ្ធសាស្ត្រនានាដល់បុគ្គលិកផ្នែកកុមារភាព ដើម្បីជួយជំរុញការវិវឌ្ឍន៍របស់ក្មេង ។ កម្មវិធីអន្តរាគមន៍កុមារភាព ក៏អាចជួយដល់គ្រួសារទាំងឡាយ ក្នុងការស្វែងរក និងទាក់ទងរកសេវាកម្ម និងការគាំទ្រជាច្រើនប្រភេទរបស់សហគមន៍ ។



## តើក្មេងៗ និងគ្រួសារទាំងឡាយទទួលបានការគាំទ្រ និងសេវាកម្មនានា នៅឯណា?

គេអាចផ្តល់សេវាកម្មទាំងនេះ ក្នុងកំឡុងពេលនៃសកម្មភាពប្រចាំថ្ងៃរបស់ក្មេង នៅឯផ្ទះ ឬនៅក្នុងសហគមន៍ នៅតាមទារកដ្ឋាន មត្តេយ្យសាលា កន្លែងក្មេងលេង និងក្នុងកម្មវិធី Head Start ។

## តើគ្រួសារទាំងឡាយគួរទាក់ទងទៅអ្នកណា បើសិនជាកូនរបស់ពួកគេ មានសិទ្ធិទទួលបានកម្មវិធីអន្តរាគមន៍កុមារភាពនេះ?

ជំហានដំបូងសំរាប់គ្រួសារណាមួយដែលមានកង្វល់អំពីការវិវឌ្ឍន៍ របស់កូនពួកគេ ត្រូវទូរស័ព្ទទៅផ្នែកបម្រើសេវាកម្មរបស់ CONNECT (លេខទូរស័ព្ទឥតគិតថ្លៃ: 1-800-692-7288) ឬទៅកាន់កម្មវិធី EI ប្រចាំតំបន់របស់ពួកគេ ។ កម្មវិធីអន្តរាគមន៍កុមារភាព នឹងសំរេចថាតើកូនរបស់លោកអ្នក មានសិទ្ធិទទួលបានកម្មវិធីនេះឬអត់ ។

រដ្ឋ Pennsylvania & កម្មវិធីអន្តរាគមន៍កុមារភាព



## មានសំណួរអំពី
## កម្មវិធីអន្តរាគមន៍កុមារភាព?

**ទូរស័ព្ទទៅ CONNECT**
**1-800-692-7288**
(អាចទាក់ទងតាម TTY)

CONNECT ភ្ជាប់ទំនាក់ទំនងជាមួយគ្រួសារទាំងឡាយជាមួយ មនុស្សដែលផ្ដល់ជំនួយ ។

**វែបសាយថ៍របស់ PaTTAN**
http://www.pattan.net

**វែបសាយថ៍របស់ PDE**
http://www.education.state.pa.us

**វែបសាយថ៍របស់ DPW**
http://www.dpw.state.pa.us





## កម្មវិធី EI ប្រចាំតំបន់លោកអ្នក

PA pennsylvania
EARLY INTERVENTION
*Serving Children with Developmental Delays*